







## តើមានសកម្មភាពអ្វីខ្លះដែល ត្រូវហាមឃាត់ ?

១. ដុត និង កាប់ព្រៃឈើ ដើម្បីយកដីធ្វើកម្មសិទ្ធ
២. សង់ឡដុតធ្យូងដោយគ្មានច្បាប់អនុញ្ញាត
៣. រានដីព្រៃថ្មីដើម្បីសង់ផ្ទះដោយគ្មានដីកម្មសិទ្ធផ្ទាល់ខ្លួន
៤. ដាំដុះដំណាំលើដីកម្មសិទ្ធផ្ទាល់ខ្លួន ដោយធានាមិនរានដីព្រៃថ្មីមកធ្វើកម្មសិទ្ធបន្ថែម
៥. ពង្រីកដីព្រៃយកធ្វើកម្មសិទ្ធលើសដីកម្មសិទ្ធរបស់ខ្លួន
៦. ប្រមូលអនុផលព្រៃឈើមកធ្វើជំនួញលើសពីសិទ្ធប្រើប្រាស់ជាប្រពៃណី





F016

## សូមជួយការពារខេត្តកោះកុង



## ហេតុអ្វីយើងត្រូវទប់ស្កាត់ការកាប់ទន្ទ្រានយកដីព្រៃ ?

១. ការកាប់ទន្ទ្រានយកដីព្រៃ គឺជាទង្វើប្រឆាំងនឹងផែនការប្រើប្រាស់ដីរបស់អាជ្ញាធរខេត្ត និងរដ្ឋាភិបាល ។
២. ការកាប់ទន្ទ្រានយកដីព្រៃ គឺជាទង្វើមួយបំផ្លាញព្រៃឈើដែលត្រូវបានការពារ និង អភិរក្សដោយរាជរដ្ឋាភិបាល ។
៣. ការកាប់ទន្ទ្រានយកដីព្រៃ គឺបំផ្លាញជំរកសត្វព្រៃនៅក្នុងខេត្តកោះកុង និងបំផ្លាញបេតិកភ័ណ្ឌជាតិ ។





## តើច្បាប់របស់រាជរដ្ឋាភិបាលចំពោះការកាប់ទន្ទ្រានដីព្រៃយ៉ាងដូចម្តេច ?

១. អ្នកកាប់ទន្ទ្រានយកដីព្រៃត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ០៥ ឆ្នាំ ទៅ ១០ ឆ្នាំ ដោយមិនអាចយកប្រាក់មកធានា ឬ ពិន័យជំនួសបានឡើយ ។
២. អ្នកប្រព្រឹត្តល្មើសត្រូវចាកចេញពីដីជាបន្ទាន់ដោយគ្មានសិទ្ធទាមទារសំណងអំពីពលកម្មអ្វីឡើយ ទោះបីជាអ្នកនោះបានចំណាយប្រាក់ និង ពេលវេលាចំពោះសកម្មភាពរបស់ខ្លួនក៏ដោយ ។





នាយកដ្ឋានរុក្ខា-ប្រមាញ់ អង្គការជំនួយសត្វព្រៃ និង កងរាជអាវុធហត្ថលើផ្ទៃប្រទេសបានបង្កើតនូវក្រុមដើរល្បាត ដើម្បីការពារដីព្រៃឈើ ។ លោកលោកស្រីនឹងឃើញក្រុមទាំងនេះដើរល្បាតនៅក្នុងខេត្តកោះកុង ។ ក្រុមទាំងនេះមានសិទ្ធិបញ្ឈប់នូវការកាប់ទន្ទ្រានដីព្រៃ ព្រមទាំងសកម្មភាពខុសច្បាប់ផ្សេងៗទៀត ដូចជា: ការកាប់ឈើខុសច្បាប់ ការបរបាញ់សត្វព្រៃ ការសង់ឡដុតធ្យូង រោងចក្រផលិតម្សៅរល្លីវមៀត ប្រេងខ្លឹមច័ន្ទ ប្រេងទេព្វិរូ និង ការប្រមូលអនុផលព្រៃឈើមកធ្វើជំនួញ ។

កោះកុង គឺជាផ្លូវធ្វើដំណើររបស់ហ្វូងដំរីនៅសល់ជាចុងក្រោយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ រាជរដ្ឋាភិបាល និង ឯកឧត្តមអភិបាលខេត្តមានអទិភាពដើម្បីការពារដំរី ព្រៃឈើ វាលស្មៅ ស្ទឹងទន្លេ និង តំបន់ឆ្នេរសមុទ្រកោះកុង ។ ទាំងនេះ គឺជាទ្រព្យសម្បត្តិ និងកេរ្តិ៍តំណែលធម្មជាតិសំរាប់ប្រជាជនកម្ពុជា និង ជាមោទនភាពរបស់រាជរដ្ឋាភិបាល ។ ទាំងនេះ ត្រូវបានគ្រោងឡើងដើម្បីរក្សាសោភ័ណភាពខេត្តកោះកុងឱ្យក្លាយទៅជាគោលដៅសេដ្ឋកិច្ចទេសចរណ៍ និងថែរក្សាបរិស្ថានធម្មជាតិ សំរាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងខេត្ត ។

WildAid